ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ១៤ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមានៈ

- ច្បាប់
- ក្រម- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៧-៤-១៩៩៥ - ព្រះរាជក្រឹត្យ លេខ នស/រកត/០៤៩៥/៣៧
ស្តីពីការតែងតាំង លោក សុខ គង់ ជាឧញ្ញ៉ា ៥៩៣

១៧-៤-១៩៩៥ - ព្រះរាជក្រឹត្យ លេខ នស/រកត/០៤៩៥/៣៨
ស្តីពីការតែងតាំងលោក លឹម ហុងឈាង ជាឧញ្ញ៉ា ៥៩៣

១៧-៤-១៩៩៥ - ព្រះរាជក្រឹត្យ លេខ នស/រកត/០៤៩៥/៣៩/
ស្តីពីការតែងតាំងលោក ស៊ិន សុខា ជាឧញ្ញ៉ា ៥៩៤

២១-៤-១៩៩៥ - ព្រះរាជក្រឹត្យ លេខ នស/រកត/០៤៩៥/៤០ ៥៩៥

II-ទីស្តីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

១៩-៤-១៩៩៥ - អនុក្រឹត្យ លេខ ៣៨ អនក្រ ស្តីពីបែបបទ នៃ
នៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ៥៩៦

២០-៤-១៩៩៥ - អនុក្រឹត្យ លេខ៤៥ អនក្រ ស្តីពីការអោយចូលនិវត្តន៍
មន្ត្រីរាជការ ៦០២

២០-៤-១៩៩៥ - អនុក្រឹត្យ លេខ ៤៦ អនក្រ ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦០៣

២-សេចក្តីសំរេច

១៩-៤-១៩៩៥ - សេចក្តីសំរេច លេខ ៣៦ សសរ ស្តីពីការប្រគល់ដីស្រែ
របស់សាលានាយទាហាន នៃកងយោធពលខេមរភូមិន្ទ
ជូនទៅប្រជារាស្ត្រ ក្នុងឃុំជីណាក់រាំង ស្រុកឧត្តុង្គ ខេត្ត
កំពង់ស្ពឺ ៦០៥

២០-៤-១៩៩៥ - សេចក្ដីសំរេច លេខ ៣៧ សសរ ស្ដីពីការបង្កើតគណៈកម្មការ អង្កេតស្រាវជ្រាវករណី បោះពុម្ពលិខិតឆ្លងដែនថ្មី ៦០៦

III-ការងារបណ្ដាក្រសួង

១ - ទីស្ដីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

១៨-៤-១៩៩៥ - ប្រកាស លេខ ៣០១ ផក ប្រក ស្ដីពីការអនុញ្ញាតអោយ លោក ចាន់ សេង ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ ៦០៩

១៨-៤-១៩៩៥ - ប្រកាស លេខ ៣០២ ផក ប្រក អនុញ្ញាតអោយលោក សុខ អ៊ីង ជនជាតិខ្មែរ បើកដំណើរការផលិតកម្ម ការ៉េម និងទឹកកកដើម ៦០៩

១៨-៤-១៩៩៥ - ប្រកាស លេខ ៣០៣ ផក ប្រក អនុញ្ញាតអោយអ្នកស្រី គុណ តារាច័ន្ទ ជនជាតិខ្មែរ បើកដំណើរការឧស្សាហកម្ម តូចផលិតទឹកបរិសុទ្ធCRYSTAL CLEAR WATER ៦១០

១៨-៤-១៩៩៥ - ប្រកាស លេខ ៣០៤ ផក ប្រក អនុញ្ញាតអោយលោក មួន ឡាយ ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មទឹកស៊ីអ៊ីវ សញ្ញា«រូបចុងភៅស្រី» និងទឹកម្ទេសជ្រក់ សញ្ញា«ថាសហោះ»៦១០

១៨-៤-១៩៩៥ - ប្រកាស លេខ ៣០៥ ផក ប្រក អនុញ្ញាតអោយលោក កួយ ស៊ិន ជនជាតិខ្មែរ បើកដំណើរការផលិតកម្មទឹកកកដើម ៦១១

១៨-៤-១៩៩៥ - ប្រកាស លេខ ៣០៦ ផក ប្រក អនុញ្ញាតអោយលោក ស្រី ជា ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង៦០សេះ៦១១

១៨-៤-១៩៩៥ - ប្រកាស លេខ ៣០៧ ផក ប្រក អនុញ្ញាតអោយអ្នកស្រី រ័ត្ន សាមឿន ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ

	កំលាំង ៦៥ សេះ	៦១២
១៨-៤-១៩៩៥	- ប្រកាស លេខ ៣០៨ ផក ប្រក អនុញ្ញាតអោយលោក ភិន សារ៉ុធ ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ	៦១២
១៨-៤-១៩៩៥	- ប្រកាស លេខ ៣០៩ ផក ប្រក អនុញ្ញាតអោយលោក អិន ហ៊ុម ជនជាតិខ្មែរ បើកដំណើរការផលិតកម្មទឹកកកដើម	៦១២

២- ទីស្តីការក្រសួងធម្មការ និងសាសនា

ប្រកាស

២១-៤-១៩៩៥	- ប្រកាស លេខ ៧៨/៩៥ កធស ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ	៦១៤

៣- រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ

សេចក្តីសំរេច

២២-៤-១៩៩៥	- សេចក្តីសំរេច លេខ ២៥០ សសរ មស ក្រខ ស្តីពីការកែតំរូវសេចក្តីសំរេចលេខ ២១៩ សសរ មស ក្រខ ចុះថ្ងៃទី ៣០-៣-១៩៩៥	៦១៥
២២-៤-១៩៩៥	- សេចក្តីសំរេច លេខ ២៥១ មស ក្រខ ស្តីពីការកែតំរូវសេចក្តីសំរេចលេខ ២៣៣ សសរ មស ក្រខ ចុះថ្ងៃទី ៥-៤-១៩៩៥	៦១៦

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៣៧

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក សុខ គង់

ជា

ឧកញ៉ា

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

ព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៣៨

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក លឹម ហុងឈាង

ជា

ឧកញ៉ា

រាជធានីភ្នំពេញ ថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

ព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៣៩

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ស៊ិន សុខា

ជា

ឧកញ៉ា

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

ព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២នៃរាជរដ្ឋាភិបាល
- បានទ្រង់យល់ ព្រះរាជក្រម លេខ ០២នស ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់កិច្ចព្រមព្រៀង ខ្មែរ- បារាំង ចុះថ្ងៃទី ២៥- ០២- ១៩៩៤ ស្តីពីការរៀបចំឡើងវិញនូវសាលាភូមិន្ទរដ្ឋបាលប្រចាំនៅកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងដោយគណៈរដ្ឋមន្ត្រីបានយល់ព្រមផងតាមរយៈការប្រជុំពេញអង្គ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៥

ត្រាស់បង្គាប់

មាត្រា១ : បង្កើតសាលាភូមិន្ទរដ្ឋបាល ចំណុះទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២ : សាលាភូមិន្ទរដ្ឋបាលមានភារកិច្ចជ្រើសរើសបណ្តុះបណ្តាល និងរិក្រឹតការមន្ត្រីរាជការដែលត្រូវគ្រប់គ្រងការងារព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : សាលាភូមិន្ទរដ្ឋបាល ត្រូវបានដឹកនាំដោយមន្ត្រីជាន់ខ្ពស់មួយរូប អមដោយក្រុមប្រឹក្សាភិបាល ។

មាត្រា ៤ : លក្ខន្តិកៈ នៃសាលាភូមិន្ទរដ្ឋបាល ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ និងសហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ ។

មាត្រា ៧ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានបញ្ញត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

II-ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៣៨ អនក្រ

ស្តីពីរបៀបចងនៃឯកជនភាវូបនីយកម្ម

សមាគ្រាសសាធារណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម លេខ ១០ នស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពី ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- តាមសំណើររបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : សមិទ្ធកម្មនៃកិច្ចប្រតិបត្តិការឯកជនភាវូបនីយកម្មសហគ្រាស និងទ្រព្យសកម្ម សាធារណៈផ្សេងទៀត ដូចដែលបានកំណត់ក្នុងមាត្រា ៨១ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ ការគ្រប់គ្រងឆ្នាំ ១៩៩៥ ត្រូវបានសំរេចទៅតាមបែបបទ ដែលបានកំណត់ដោយ អនុក្រឹត្យ នេះ ។

មាត្រា ២ : ត្រូវបានស្ថិតនៅក្រៅដែនអនុវត្តនៃបទបញ្ញានេះ រួមមានសកម្មភាពទាំងឡាយ ដែលទាក់ទងទៅនឹងការការពារ និងសន្តិសុខហើយនិងបេតិកភ័ណ្ឌវប្បធម៌ ។

មាត្រា ៣ : ការងារឯកជនភាវូបនីយកម្មសហគ្រាស និងទ្រព្យសកម្មសាធារណៈត្រូវបានអនុវត្ត ដោយអនុលោមទៅតាមទិសដៅជាមូលដ្ឋាន នៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់ ព្រះរាជាណាចក្រកម្ពុជា ជាអាទិ៍សំដៅ :

- លើកស្ទួយអភិក្រមពង្រឹងសេដ្ឋកិច្ចទីផ្សារ និងពង្រឹងផ្នែកឯកជន ។
- លើកកំពស់ការស្តារឡើងវិញ និងអភិវឌ្ឍន៍ប្រព័ន្ធផលិតកម្មរបស់ប្រទេសជាតិ ។
- លើកកំពស់ស្មារតីប្រជាពលរដ្ឋលើបញ្ហាសហគ្រាស និងការទាក់ទាញការបង្កើត វិនិយោគទុនក្រៅប្រទេស ។

មាត្រា ៤ កិច្ចប្រតិបត្តិការឯកជនភាវូបនីយកម្មគឺជាកម្មវត្ថុមួយដែលត្រូវបានសំរេចដោយគណៈ រដ្ឋមន្ត្រីតាមសំណើររបស់ក្រសួងអាណាព្យាបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

កម្មវិធីដូចបានពោលនេះកំណត់ច្បាស់លាស់នូវបញ្ជីចំនួនសហគ្រាស និងទ្រព្យសកម្ម ដែលត្រូវធ្វើឯកជនភាវូបនីយកម្ម ប្រតិទិនសំរាប់ដាក់អនុវត្តនិតិវិធីប្រតិបត្តិការ និងវិធីធ្វើឯកជនភាវូបនីយកម្ម ។

កម្មវិធីឯកជនភាវូបនីយកម្មត្រូវបានអនុវត្តក្រោមការត្រួតពិនិត្យរបស់គណៈកម្មាធិការឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ដែលបានបង្កើតឡើងដោយមាត្រា ៨២នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ។

ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ

ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

មាត្រា ៥ : គណៈកម្មាធិការមានសមត្ថកិច្ចដូចតទៅ ÷

- រៀបចំគំរោង នៃកម្មវិធីឯកជនភាវូបនីយកម្ម
- ចងក្រងយុទ្ធសាស្ត្រអនុវត្ត និងគំនូសបំព្រួញនៃការងារឯកជនភាវូបនីយកម្ម
- ពិនិត្យឡើងវិញនូវកិច្ចប្រតិបត្តិការត្រៀមបំរុងសំរាប់ឯកជនភាវូបនីយកម្មជាអាទិ៍ គឺអ្វីដែលពាក់ព័ន្ធនឹងការវាយតំលៃទ្រព្យសកម្ម ការបញ្ជាក់លក្ខន្តិកៈគតិយុត្តិនៃទ្រព្យសកម្ម ឬសហគ្រាស ការជំរះបំណុល និងឥណទេយ្យ និងផែនការកាត់បន្ថយចំនួនបុគ្គលិកក្នុងករណីចាំបាច់ ។
- អនុម័តលើចំណុចសំខាន់ៗ ជាគតិយុត្តិ នៃកិច្ចការជំនួញជាអាទិ៍ កិច្ចសន្យា និងសៀវភៅបន្ទុករបស់ឯកជនភាវូបនីយកម្ម ។
- ត្រួតពិនិត្យភាពទៀងទាត់ នៃនិតិវិធីឯកជនភាវូបនីយកម្មជាអាទិ៍ ការប្រកាសដេញថ្លៃ ការពិនិត្យកិច្ចសន្យាទទួលការ និងការជ្រើសរើសយកលទ្ធជន ។

មាត្រា ៦ : គណៈកម្មាធិការឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈមានសមាសភាពដូចតទៅ ÷

- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង	ប្រធាន
- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឬតំណាង	សមាជិក
- រដ្ឋមន្ត្រីក្រសួងផែនការ ឬតំណាង	សមាជិក
- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬតំណាង	សមាជិក

- រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន ឬតំណាង សមាជិក
- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង សមាជិក
- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬតំណាង សមាជិក
- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន ឬតំណាង សមាជិក
- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬតំណាង សមាជិក
- ទេសាភិបាលធនាគារជាតិនៃកម្ពុជា ឬតំណាង សមាជិក
- រដ្ឋមន្ត្រីអាណាព្យាបាល ឬតំណាង សមាជិក
- ប្រធានសហគ្រាសដែលមានការពាក់ព័ន្ធតាមការពិភាក្សាសំរេចព្រមទាំងបុគ្គលដទៃទៀតតាមការចាំបាច់ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធានាអោយមានលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការព្រមទាំងការកេណ្ឌមធ្យោបាយមនុស្ស និងសំភារៈចាំបាច់សំរាប់ដំណើរការគណៈកម្មាធិការ ។

មាត្រា ៧ : គណៈកម្មាធិការឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈក្តាប់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬដោយរដ្ឋមន្ត្រីអាណាព្យាបាល ។ គណៈកម្មាធិការនេះត្រូវធ្វើការប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន ។

មាត្រា ៨ : សេចក្តីសំរេចទាំងឡាយស្តីពីឯកជនភាវូបនីយកម្មត្រូវបានប្រកាសដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់គណៈកម្មាធិការឯកជនភាវូបនីយកម្មសហគ្រាស សាធារណៈ ។

នីតិវិធីនៃនីតិវិធី

មាត្រា ៩ :- រាល់កិច្ចប្រតិបត្តិការឯកជនភាវូបនីយកម្ម ដែលធ្វើឡើងដោយអាណាព្យាបាលសហគ្រាសត្រូវកសាងសំណុំឯកសារមួយ ដើម្បីឆ្លងមតិយោបល់យល់ព្រមពីគណៈកម្មាធិការឯកជនភាវូបនីយកម្ម ។

សំណុំឯកសាររួមមានដូចតទៅ :

- កំណត់បង្ហាញសហគ្រាស
- គំរោងសៀវភៅបន្ទុកនៃឯកជនភាវូបនីយកម្ម

- តំនួសបំព្រួញនៃឯកជនភាវូបនីយកម្មដែលបានស្នើឡើង

មាត្រា១០:- តំនួសបំព្រួញនៃឯកជនភាវូបនីយកម្ម ដែលបានរក្សាទុកត្រូវសមស្រប នឹងទំហំរបស់សហគ្រាស និងប្រភេទនៃសកម្មភាព ដែលមានការពាក់ព័ន្ធ ។ ទៅតាមករណីតំនួសបំព្រួញទាំងឡាយនៃឯកជនភាវូបនីយកម្មទាំងមូល ឬមួយចំណែកសម្បទាន ឬអនុប្បទានទ្រព្យសកម្មដោយឡែកអាចត្រូវបានរក្សាទុកសំរាប់ការផ្ទេរសហគ្រាស និងទ្រព្យសកម្មសាធារណៈផ្សេងទៀតទៅអោយផ្នែកឯកជន ។

មាត្រា១១ :- កិច្ចការជំនួញដែលបានអនុវត្តក្នុងក្របខ័ណ្ឌនៃកិច្ចប្រតិបត្តិការឯកជនភាវូបនីយកម្មមួយត្រូវបានសំរេចតាមរយៈការដេញថ្លៃផ្ទាល់មាត់ក្រោយពីការផ្សព្វផ្សាយដ៏ទូលំទូលាយ ។ ប្រសិនបើក្នុងករណីដែលការដេញថ្លៃមិនបានសំរេចផលទេ ដោយមានការកត់សំគាល់ត្រឹមត្រូវនោះគេអាចត្រឡប់មកនីតិវិធីស្រុះស្រួលគ្នាវិញ ។

មាត្រា១២ :- ក្នុងករណីដេញថ្លៃ ឬពិគ្រោះថ្លៃ ការបើកស្រោមសំបុត្រ និងកិច្ចសន្យាទទួលការត្រូវប្រព្រឹត្តទៅដោយគណៈកម្មាធិការមួយដែលមានសមាសភាពកំណត់ដោយអនុក្រឹត្យ ។ លទ្ធផលនៃការដេញថ្លៃត្រូវបានកត់ទុកក្នុងរបាយការណ៍សំងាត់ ហើយប្រធានគណៈកម្មាធិការដេញថ្លៃនេះ ត្រូវបង្ហាញដោយផ្ទាល់ទៅគណៈកម្មាធិការភាវូបនីយកម្មសហគ្រាសសាធារណៈ ។

មាត្រា១៣ :- ដើម្បីធ្វើអោយបានសំរេចកិច្ចប្រតិបត្តិការ ដែលបានកំណត់ក្នុងមាត្រា១០ ខាងលើជាបឋមគប្បីចាត់និតិវិធីវាយតំលៃសហគ្រាស ឬទ្រព្យសកម្ម ដែលជាមុខសញ្ញានៃឯកជនភាវូបនីយកម្ម ។

ការវាយតំលៃនេះត្រូវបានធ្វើឡើងដោយអ្នកជំនាញការឯករាជ្យ ដែលមានការតែងតាំងពីអាណាព្យាបាលសហគ្រាស ។ ការតែងតាំងនេះត្រូវបានទទួលការឯកភាពពីគណៈកម្មាធិការឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ។

មាត្រា ១៤ :- កិច្ចប្រតិបត្តិការទាំងអស់ដែលទាក់ទង នឹងឯកជនភាវូបនីយកម្ម ចាប់តាំងពីការវាយតំលៃសហគ្រាសរហូតដល់ការសំរេចកិច្ចសន្យាលក់ ត្រូវធ្វើតាម លក្ខការណ៍សំងាត់បំផុត ។ អ្នកធ្វើអន្តរាគមន៍ត្រូវប្រកាន់ជំហរអោយបានត្រឹម

ត្រូវតាមគោលការណ៍នេះ បើពុំនោះទេត្រូវទទួលពិន័យដែលបានកំណត់តាមច្បាប់ជាធរមាន ។

មាត្រា១៥ :- រាល់កិច្ចប្រតិបត្តិការ នៃឯកជនភាវូបនីយកម្ម ត្រូវបង្កើតសៀវភៅបន្ទុកមួយ ដែលរៀបចំឡើងក្រោមការទទួលខុសត្រូវ នៃអាណាព្យាបាលរបស់សហគ្រាសពាក់ព័ន្ធ ហើយដាក់ជូនគណៈកម្មាធិការឯកជនភាវូបនីយកម្ម ដើម្បីសុំការយល់ព្រម ។

មាត្រា ១៦ :- សៀវភៅបន្ទុកបញ្ជាក់ច្បាស់លាស់នូវលក្ខខ័ណ្ឌឯកជនភាវូបនីយកម្មជាអាទិ៍ ដូចជាបែបបទទូទាត់ និងមូលដ្ឋានហិរញ្ញវត្ថុ និងមុខរបរ នៃលទ្ធជន ។ សៀវភៅបន្ទុកអាចមានផងដែរ នូវបញ្ញត្តិមួយចំនួនស្តីពីនិរន្តភាព នៃសកម្មភាពកម្មវិធីវិនិយោគ ឬការរក្សានូវកិរិតការងារមួយដ៏សមស្រប ។

មាត្រា១៧ :- បើសិនសកម្មភាពដែលមានលក្ខណៈផ្តាច់មុខ ឬជាសេវាកម្មសាធារណៈ នោះសៀវភៅបន្ទុកត្រូវបញ្ជាក់អោយច្បាស់ជាចាំបាច់នូវលក្ខណៈសកម្មភាព នៃអាជីវកម្មដើម្បីជៀសវាងការទាញយកផលប្រយោជន៍ដ៏ហួសហេតុពីភាពផ្តាច់មុខ ពីការខ្វះចន្លោះ នៃច្បាប់សាធារណៈ ។

ការចូលរួមរបស់បុគ្គលិក និងវិនិយោគិនក្រៅប្រទេស

មាត្រា១៨ :- អត្ថប្រយោជន៍ពិសេសអាចត្រូវបានផ្តល់អោយនិយោជិក និងក្របខ័ណ្ឌ បេក្ខជនទាំងឡាយដែលធ្វើលទ្ធកម្ម(ទិញ) សហគ្រាសរបស់ខ្លួន ឬមួយចំណែកណានោះ នៃទ្រព្យ សកម្មរបស់ខ្លួន ។

អត្ថប្រយោជន៍ទាំងនេះ ដែលត្រូវបានយល់ព្រមពីគណៈរដ្ឋមន្ត្រី លើសំណើរបស់គណៈកម្មាធិការឯកជនភាវូបនីយកម្មអាចផ្តល់ជាអាទិភាព នូវសិទ្ធិលទ្ធកម្មសហគ្រាស ឬទ្រព្យសកម្មសមស្របជាយថាហេតុ និងជាលក្ខណៈពិសេស នៃថ្លៃ និងរយៈពេល នៃការទូទាត់ ។

មាត្រា១៩ :- តាមលក្ខខ័ណ្ឌ នៃបទបញ្ញត្តិអាស្រ័យដោយរដ្ឋធម្មនុញ្ញ និងនិត្យានុកូលស្តីពីកម្មសិទ្ធិដីធ្លីរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាបរទេស និវាសជន ឬមិនមែននិវាសជនអាចចូលរួមចំណែកចំពោះកិច្ចប្រតិបត្តិការឯកជនភាវូបនីយកម្មនេះបានដែរ ។

បទបញ្ញត្តិទាំងឡាយនៅក្នុងមាត្រា១៦នៃព្រះរាជក្រមលេខ ០៣ នស ចុះថ្ងៃទី៥ ខែ សីហា ឆ្នាំ១៩៩៤ ស្តីពីការវិនិយោគអាចអនុវត្តបានចំពោះកិច្ចប្រតិបត្តិការឯកជនភាវូបនីយកម្ម ។

មាត្រា ២០ :- កិច្ចប្រតិបត្តិការឯកជនភាវូបនីយកម្ម ដែលបានអនុវត្តនៅក្នុងក្របខ័ណ្ឌនៃអនុក្រឹត្យនេះ ត្រូវបានជ្រើសតាំងទៅតាមអត្ថប្រយោជន៍ ដែលបានចែងក្នុងព្រះរាជក្រមលេខ ០៣ នស ចុះថ្ងៃទី ៥ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីវិនិយោគត្រឹមត្រូវតាមបែបបទដែលបានចែងដោយច្បាប់ដូចដែលបានពោលខាងលើ និងអត្ថបទក្រោយៗ ទៀត ។

អវសានប្បញ្ញត្តិ

មាត្រា ២១ :- ចំណូលដែលបានមកពីការធ្វើឯកជនភាវូបនីយកម្មនៃសហគ្រាស និងទ្រព្យសកម្ម សាធារណៈផ្សេងទៀត ត្រូវបញ្ចូលទៅក្នុងគណនីពិសេសមួយនៅរតនាគារស្រប តាមបទបញ្ញត្តិទាំងឡាយដែលបានចែងក្នុងមាត្រា ៨៣ ដល់ ៨៦ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ។

មាត្រា ២២ :- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ២៣ :- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	**នាយករដ្ឋមន្ត្រីទី២**
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៤៥ អនក្រ

ស្តីពី

ការអោយចូលនិវត្តន៍មន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា១ : ត្រូវបានអោយចូលនិវត្តន៍ លោក**លឹម ឯម** បច្ចុប្បន្ន ជាអភិបាលស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ។

មាត្រា២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួង សង្គមកិច្ច ការងារ និងអតីតយុទ្ធជន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អភិបាលខេត្តព្រៃវែង ព្រមទាំងលោក**លឹម ឯម** ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ៕

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៤៦ អនក្រ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

---==«00»==---

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤របស់រាជរដ្ឋាភិបាលស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

សំរេច

មាត្រា ១: ត្រូវបានប្រគល់មេដាយស្ថាបនាជាតិតាមលំដាប់ថ្នាក់ ប្រគេន និងជូនចំពោះសប្បុរសជនដែលមានសទ្ធាជ្រះថ្លាបានបរិច្ចាគថវិកាផ្ទាល់ខ្លួនចូលរួមចំណែកសាងសង់ព្រះវិហារ និងសាលារៀននៅក្នុងវត្តកំពង់សំបួរ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ដូចមានរាយព្រះនាម និងនាមខាងក្រោម ÷

ក-មេដាយស្ថាបនាជាតិថ្នាក់លេខ ១:

១-ព្រះគ្រូបបញ្ញានុរក្ខិត **ហ៊ី សុភា** ជោតបញ្ញោ អនុគណៈស្រុកកោះធំ និងជាចៅអធិការវត្តកំពង់សំបួរ

ខ-មេដាយស្ថាបនាជាតិថ្នាក់លេខ ២:

១-លោក **សាយ ឈុនឆង** ទឹកប្រាក់ ៩.៥០០ ដុល្លារអាមេរិក

២-លោក **ឆៀង មៀង** ទឹកប្រាក់ ៥.៥០០ ដុល្លារអាមេរិក

គ-មេដាយស្ថាបនាជាតិថ្នាក់លេខ ៣:

១-លោក **ឡូក គួក** ទឹកប្រាក់ ៤.៥០០ ដុល្លារអាមេរិក

២–លោក សេង សែម ទឹកប្រាក់ ៤.៥០០ ដុល្លារអាមេរិក

៣–លោក គីម ជាង ទឹកប្រាក់ ៤.៤៥០ ដុល្លារអាមេរិក

៤–លោក ឌី ស្រ៊ិន ទឹកប្រាក់ ៤.៤៥០ ដុល្លារអាមេរិក

៥–លោក គាន ឯម ទឹកប្រាក់ ៤.៤៥០ ដុល្លារអាមេរិក

១៤–លោក ឈាម ឈាងអាំង ទឹកប្រាក់ ៤.១០០ ដុល្លារអាមេរិក

មាត្រា ២: សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

២- សេចក្ដីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥

សេចក្ដីសំរេចលេខ : ៣៦ សសរ

ស្ដីពី

ការប្រគល់ដីស្រែរបស់សាលានាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូនទៅប្រជារាស្ត្រក្នុងឃុំដំណាក់អាំង ស្រុកឧត្ដុង្គ ខេត្ត កំពង់ស្ពឺ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ របស់ព្រះករុណា ព្រះបាទសម្ដេច នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់គណៈកម្មាធិការអន្តរក្រសួង ដោះស្រាយពាក្យបណ្ដឹង

របស់ប្រជារាស្ត្រ ស្រុកខ្សាច់កណ្តាល ខេត្តកំពង់ស្ពឺ លេខពិសេស ចុះថ្ងៃទី ២០ ខែ ១១ ឆ្នាំ ១៩៩៤

សំរេច

ប្រការ ១ : ប្រគល់ដីស្រែចំនួន ២៣ ហិកតា ក្នុងពោះអូរស្ពានទំនប់បាក់ ដែលស្ថិតនៅខាងកើត ភូមិពោធិ ឃុំដំណាក់រាំង ជូនទៅប្រជារាស្ត្រវិញ ។

ប្រការ ២ : ប្រគល់ដីផ្នែកខាងលិចសាលាចំនួន ៧៥ ហិកតា ដែលកន្លងទៅអតីតសាលាទំពងជើង គោកចំរុះបានគ្រប់គ្រងលើសជូនទៅប្រជារាស្ត្រវិញ ។

ប្រការ ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និង អភិបាលខេត្តកំពង់ស្ពឺ ព្រមទាំងបណ្តាស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសំរេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

៚៚

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៣៧ សសរ

ស្តីពី

ការបង្កើតគណៈកម្មការស្រាវជ្រាវ

បោះពុម្ពលិខិតឆ្លងដែនថ្មី

៚៚

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេច នរោត្តម សីហនុ

រ៉ូន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- យោងតាមសំណូមពរការងារចាំបាច់ ។

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការមួយមានឈ្មោះថា «គណៈកម្មការអង្កេតស្រាវជ្រាវករណីបោះពុម្ពលិខិតឆ្លងដែនថ្មី» ដែលមានសមាសភាពដូចតទៅ ÷

១- ឯកឧត្តម អ៊ឹង ផន	ទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច	ប្រធាន
២- ឯកឧត្តម ញឹម វណ្ណដា	រដ្ឋមន្ត្រីប្រតិភូ បេសកជនពិសេសរបស់សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២	អនុប្រធាន
៣- ឯកឧត្តម ប៉ោ ប៊ុនស្រ៊ី	បេសកជនពិសេសរបស់សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២	អនុប្រធាន
៤- ឯកឧត្តម ស៊ី ម៉ានិត	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៥- ឯកឧត្តម នូវ កាន់ន	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៦- ឯកឧត្តម ហេង វង្សប៊ុនឆាត	អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់	សមាជិក
៧- ឯកឧត្តម កៅ ប៊ុនហុង	សមាជិកក្រុមប្រឹក្សាអ្នកច្បាប់	សមាជិក

ប្រការ ២ : គណៈកម្មការអង្កេតស្រាវជ្រាវនេះមានភារកិច្ច ÷

- ធ្វើការស្រាវជ្រាវតាំងពីដើមរហូតដល់ចប់ទាក់ទងនឹងបញ្ហាបោះពុម្ពលិខិតឆ្លងដែនថ្មី
- ស្រាវជ្រាវច្បាស់លាស់ពីបរិមាណសរុបនៃលិខិតឆ្លងដែនតាមប្រភេទនិមួយៗ

និងតំលៃពិតរបស់វា [illegible]

- សរុបរបាយការណ៍ជូនរាជរដ្ឋាភិបាល ។

ប្រការ ៣ : គណៈកម្មការអង្កេតស្រាវជ្រាវនេះ មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ ឬតំណាងក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធទៅនឹងខ្លឹមសារនៃការងារអង្កេតស្រាវជ្រាវ ដើម្បីចូលរួមបំពេញការងារនេះតាមការជាក់ស្តែង ។

ប្រការ ៤ : សមាជិកទាំងអស់ នៃគណៈកម្មការអង្កេតស្រាវជ្រាវនេះត្រូវចូលរួមប្រជុំនិងធ្វើការងារតាមសេចក្តីអញ្ជើញ និងការណែនាំរបស់ប្រធាន ។

ប្រការ ៥ : គណៈកម្មការអង្កេតស្រាវជ្រាវនេះ អាចមានសិទ្ធិបង្កើតក្រុមជំនួយការមួយដើម្បីជួយធ្វើការងាររបស់ខ្លួន ។

ប្រការ ៦ : គណៈកម្មការអង្កេតស្រាវជ្រាវនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាផ្លូវការ ។

ប្រការ ៧ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គទេសាភិបាលធនាគារជាតិកម្ពុជា និងសាមីខ្លួនដូច មានចែងក្នុងប្រការ១ ត្រូវសហការអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា និងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

III-ការងារបណ្តាក្រសួង

១- ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

ប្រកាស

ប្រកាសលេខ ៣០១ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១:–អនុញ្ញាតអោយលោក **ចាន់សេខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៥៥០៥៣ ក.ណ ចុះថ្ងៃទី ០១–១១–៩០ អាស័យដ្ឋានបច្ចុប្បន្ន ភូមិលេខ ១ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ នៅក្នុងទី តាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២:–លោក **ចាន់ សេខ** ត្រូវចាប់ផ្ដើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣:–ប្រកាសនេះមានរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះ នឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៣០២ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១:–អនុញ្ញាតអោយលោក **សុខ អ៊ុំ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ៣២០៣៣៧ ភ.ព ចុះថ្ងៃទី ១៤–០១–១៩៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៣៣១ ផ្លូវលេខ ៣៦៩ ភូមិដើមចាន់ សង្កាត់ច្បារអំពៅទី២ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ បើកដំណើរការផលិតកម្មការ៉េម និងទឹកកក ដើមនៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២:–ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផល គ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៣០៣ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១:–អនុញ្ញាតអោយអ្នកស្រី **គួណ តារាច័ន្ទ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៦១៦៥៦ ភ.ព ចុះថ្ងៃទី ១៧–០២–១៩៨៥ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ១៨ ផ្លូវលេខ ២៩៤ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ បើកដំណើរឧស្សាហកម្មតូច ផលិតទឹកបរិសុទ្ធ CRYSTAL CLEAR WATER នៅក្នុងទីតាំងផ្ទះលេខ ៥៨ ផ្លូវលេខ ២៣០ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២:–អ្នកស្រី **គួណ តារាច័ន្ទ** ត្រូវផលិតនូវមុខផលិតផលទឹកបរិសុទ្ធ CRYSTAL CLEAR WATER ស្របតាមគំរូ និងផ្លាកសញ្ញាដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ ៣:–ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៣០៤ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ :–អនុញ្ញាតអោយលោក **មួន ឡាយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៤៩៩ បប ចុះថ្ងៃទី ៣១–០៣–១៩៨៧ អាស័យដ្ឋានបច្ចុប្បន្នភូមិព្រែកមហាទេព សង្កាត់ ឯកភាព ទីរួមខេត្ត បាត់ដំបង បើកដំណើរសិប្បកម្មផលិតទឹកស៊ីអ៊ីវចុងភៅពិសេស <រូបចុងភៅស្រី> និងទឹកស៊ីអ៊ីវពិសេសសញ្ញារូប <ធំត្រមាស> និងទឹកម្ទេសជ្រក់សញ្ញា <ចាសហោះ> នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ :–លោក **មួន ឡាយ** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្មនូវមុខផលិតផលទឹកស៊ីអ៊ីវចុងភៅពិសេស <រូបចុងភៅស្រី> និង ទឹកស៊ីអ៊ីវពិសេសសញ្ញារូប <ធំត្រមាស> និងទឹកម្ទេសជ្រក់សញ្ញា <ចាសហោះ> ស្របតាមគំរូផ្លាកសញ្ញាដែល

បានតំកល់ទុកនៅក្នុងក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ ៣:–ប្រកាសនេនះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៣០៥ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១:–អនុញ្ញាតអោយលោក **គួយ សិន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ២១៤៩០៨ ប.ប ចុះថ្ងៃទី ២១–៨–១៩៩០ អាស័យដ្ឋានបច្ចុប្បន្នក្រុមទី ៧ ភូមិកំឡែបន្ទាយ ឃុំ មោង ស្រុកមោងឫស្សី ខេត្តបាត់ដំបងបើកដំណើរការផលិតកម្មទឹកកកដើមនៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២:–ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើង ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៣០៦ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១:–អនុញ្ញាតអោយលោក **ស្រី ខា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ៤០៦១៨៤ក.ណ ចុះថ្ងៃទី ២៣–៩–១៩៩៤ អាស័យដ្ឋានបច្ចុប្បន្ន ភូមិបាងឃុំដើមរើស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៦០ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២:–លោកស្រី ខា ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករ លេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣:–ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើង ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៣០៧ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១:–អនុញ្ញាតអោយអ្នកស្រី **រ័ត្ន សារម៉ឿន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ៣១២៩៩៨ ក.ណ ចុះថ្ងៃទី ២៧–១១–១៩៩១ អាស័យដ្ឋានបច្ចុប្បន្នភូមិតាឡីក ឃុំត្រពាំងវែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៦៥ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២:–អ្នកស្រី **រ័ត្ន សារម៉ឿន** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្មលើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣:–ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើង ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៣០៨ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១:–អនុញ្ញាតអោយលោក **គីម សារុន** ជនជាតិខ្មែរ សញ្ជាតិ កាន់អត្តសញ្ញាណប័ណ្ណលេខ៣៦៦៨៤៨ ក.ណ ចុះថ្ងៃទី ១៦–៨–១៩៩៤ អាស័យដ្ឋានបច្ចុប្បន្នភូមិតាឡីក ឃុំប្រពាំងវែង ស្រុកកណ្ដាល ស្ទឹង ខេត្តកណ្ដាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ នៅក្នុងទីតាំងដូច អាស័យដ្ឋានខាងលើ ។

ប្រការ ២:–លោក **គីម សារុន** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្មលើទីតាំងដែលបាន

កំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្គរលេខ ១ អោយបានយ៉ាងតិចបំផុត៦៥ ភាគរយ ។

ប្រការ ៣:–ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើង ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយ មានប៉ះពាល់ដល់បរិដ្ឋានប្រកាស នេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៣០៩ ឧក.ប្រក.ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១:–អនុញ្ញាតអោយលោក **អ៊ិន ហ៊ឹម** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ២៦២២១៩ ក.ណ ចុះថ្ងៃទី ០៩–៥–១៩៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិលេខ ៤ ឃុំព្រែកស្ដៅ ស្រុកស្អាង ខេត្តកណ្ដាល បើកដំណើរការផលិតកម្មទឹកកកដើម នៅក្នុងទីតាំងដូចអាស័យខាងលើ ។

ប្រការ ២:–ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើង ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាស នេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ពូ សុធីរៈ

២- នីស្ដីការក្រសួងធម្មការ និងសាសនា

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៧៨/៩៥ ធកស ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលចុះថ្ងៃទី ០១ - ១១ ១៩៩៣ ។
- បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ដែលប្រកាសអោយប្រើតាមក្រិត្យលេខ១៧ ក្រ ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២។
- បានឃើញអនុក្រឹត្យលេខ២២អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា ។
- បានឃើញពាក្យស្នើសុំតំលើងឋានៈ មន្ត្រីរាជការ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៩៥
- យោងទៅលើការងារចាំបាច់របស់ក្រសួង និងសមត្ថភាពរបស់មន្ត្រីរាជការ ។

សំរេច

ប្រការ១ : តែងតាំងលោក **សេខ ឈាត** បច្ចុប្បន្នប្រធានការិយាល័យបុគ្គលិក ជាអនុប្រធាននាយកដ្ឋានរដ្ឋបាល ទទួលបន្ទុកការងារបុគ្គលិក ។

- លោក **អ៊ឹ ឈាន់** បច្ចុប្បន្នអនុប្រធានការិយាល័យគណនេយ្យ ជាប្រធានការិយាល័យគណនេយ្យ ។
- អ្នកស្រី **ហ៊ុយ គន្ធា** បច្ចុប្បន្នបុគ្គលិក ជាអនុប្រធានការិយាល័យផែនការ ។

ប្រការ ២ : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល ហិរញ្ញកិច្ច និងអស់លោក អ្នកស្រី ដែលមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ។

ប្រការ ៣ : សេចក្តីប្រកាសនេះមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ហៀង ចន្ទ្រារ័ត្ន

៣—រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

ភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ២៥០ សសរ មស ក្រខ

ស្តីពីការកែតំរូវសេចក្តីសំរេចលេខ ២១៩ សសរ. មសក្រខ

ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៩៥

រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចនរោត្តម សីហនុវរ្ម័ន្ម ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស. រកត ១២៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសេចក្តីសំរេចលេខ ២១៩ សសរ. មស. ក្រខ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៩៥ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សំរេច

ប្រការ ១: កែតំរូវតារាងឧបសម្ព័ន្ធនៃសេចក្តីសំរេចលេខ ២១៩ សសរ. មស. ក្រខ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៩៥ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈដូចតទៅ ÷

ល.រ	នាមត្រកូល និងនាមខ្លួន	ភេទ	ថ្ងៃខែឆ្នាំកំណើត	អង្គភាពដើម	មុខជំនាញ	កំរិតបណ្តុះបណ្តាល	អង្គភាពចូលបំរើការងារ
				ខ្លឹមសារដើម			
២៧	ឯក ពៅ	ប	០១-០១-៦៩	សិស្ស	ស. កិអន្តរជាតិ	ឧត្តម	ក្រសួងពាណិជ្ជកម្ម
				ខ្លឹមសារកែ តំរូវ			
១២៧	ឯក ពៅ	ប	០១-០១-៦៩	សិស្ស	ស. កិអន្តរជាតិ	ឧត្តម	ក្រសួងការបរទេសសហប្រតិបត្តិការអន្តរជាតិ

ប្រការ ២:រាល់ខ្ទឹមសារផ្សេងៗពីប្រកាសខាងលើរក្សាទុកដដែល ។

ប្រការ ៣ :ខុទ្ទកាល័យ-នាយកដ្ឋានក្របខ័ណ្ឌ-នាយកដ្ឋានបៀវត្ស-ក្រសួងពាក់ព័ន្ធ និង សាមីជនមានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ឡូរ៉ាក់ សុខ

ꕥꕥ❀ꕥꕥ

ភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ២៥១ មស ក្រខ ស្តីពី

ការកែតម្រូវសេចក្តីសំរេចលេខ ២៣៣ សសរ.មស.ក្រខ

ចុះថ្ងៃទី ០៥ ខែ ៤ ឆ្នាំ ១៩៩៥

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១២៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល ។

-យោងសេចក្តីសំរេចលេខ ២៣៣ សសរ.មស. ក្រខចុះថ្ងៃទី ០៥- ៤-៩៩៥ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

សំរេច

ប្រការ ១:កែតម្រូវតារាងឧបសម្ព័ន្ធនៃសេចក្តីសំរេចលេខ ២៣៣ សសរ.មស.ក្រខ ចុះថ្ងៃទី ០៥-៤-៩៥ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈដូចតទៅ ៖

ល.រ	នាមត្រកូល នាមខ្លួន	ភេទ	ថ្ងៃខែឆ្នាំ កំណើត	អង្គភាពដើម	មុខជំនាញ បច្ចេកទេស	ក្រិតបណ្ដុះ បណ្ដាល	អង្គភាព ចូលបំរើការងារ	បៀវត្ស
១០៨១	ប៊ុន ឆេន	ប	១៥-០៨-៧០	ខ្ទីមសារដើម សិស្ស	វគ្គកម្ម	មធ្យម	ក្រ.គ្រប់គ្រង បរិដ្ឋាន	៩០.ខ II១
១០៨១	ប៊ុន ឆេន	ប	១៥-០៨-៧០	ខ្ទីមសារកែតំរូវ សិស្ស	វគ្គកម្ម	មធ្យម	ក្រ.កសិកម្ម រុក្ខា.នេសាទ	៩០.ខ II១

ប្រការ២: រាល់ខ្ទីមសារផ្សេងៗ ពីប្រការខាងលើនេះ រក្សាទុកដដែល ។

ប្រការ៣: ខុទ្ទកាល័យ នាយកដ្ឋានក្របខ័ណ្ឌ នាយកដ្ឋានបៀវត្ស ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីជនមានភារកិច្ចអនុវត្តសេចក្ដីសំរេចនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ឡោក់ សុខ

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

អស់ថ្លៃ ៤៦២ រៀល